# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

+ Standard of review

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៨៧៥
ចុះថ្ងៃទី២០-៨-២០១៨
សាលដីកា
លេខ:៦៥ ក្រឧប
ចុះថ្ងៃទី១៦-៧-២០១៨

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-៧-២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលមានសមាសភាពដូចខាងក្រោម:

ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធាន
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោកស្រី [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញា

ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងសកាព្រហ្មទណ្ឌលេខ ៨៧៥ ចុះថ្ងៃទី២០-៨-២០១៨ របស់សាលាឧទ្ធរណ៍ ដែលមាន:

**-ជនជាប់ចោទ:**

១/ឈ្មោះ [redacted] គុមភន់ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិឡាវ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃុំខ្លួនស្រុកប៉ាគីម នគរហ្លួង-វៀងចន្ទ ប្រទេសឡាវ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន។

-ឃុំខ្លួនថ្ងៃទី២៨-១២-២០១២។ (នៅពន្ធនាគារ **ខេត្តសៀមរាប**)

២/ឈ្មោះ [redacted] ខាំវៃ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិឡាវ ទីកន្លែងកំណើតស្រុកប៉ាកថង ខេត្តចំប៉ាសាក់ ប្រទេសឡាវ និងទីលំនៅមុនពេលឃុំខ្លួនស្រុកសុខុមម៉ា ខេត្តចំប៉ាសាក់





Scanned with CamScanner

ប្រទេសឡាវ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០៥នាក់ ទោសពីមុនគ្មាន។

-ឃុំខ្លួនថ្ងៃទី២៨-១២-២០១២។ (នៅពន្ធនាគារ **ខេត្តសៀមរាប**)

-មានអ្នកបកប្រែភាសា លោកស្រី [redacted] ចាន់សុជា

**ត្រូវជាប់ចោទពីបទៈ** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារបូលីណាផាឡេស ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣-១២-២០១២។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពីអង្គហេតុ**

នៅថ្ងៃទី២៣-១២-២០១២ វេលាម៉ោង ១៤:១៥នាទី ដោយអនុវត្តវិធានញុះញង់ឲ្យលក់ខុសច្បាប់នូវសារធាតុញៀន កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន និងដោយមានការដឹកនាំសម្របសម្រួលដោយតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចុះប្រតិបត្តិការបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចមុខសណ្ឋាគារបូលីណាផាឡេស បន្ទប់លេខ ៥០៣ ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងបានឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] ថង និងឈ្មោះ [redacted] ស៊ុត ពេលកំពុងធ្វើសកម្មភាពប្រព្រឹត្តបទល្មើសជាក់ស្តែង យកថ្នាំប្រភេទគ្រាប់ផ្កាឈូកសង្ស័យថា ជាគ្រឿងញៀនលាក់ទុកក្នុងការបូបមៅប្រគល់ឲ្យម៉ូយ ក្រោមការបញ្ជាពីឈ្មោះ សម្រស់ និងឈ្មោះ ផល្លី ព្រមទាំងដកហូតបានវត្ថុតាងប្រភេទថ្នាំគ្រាប់ពណ៌ផ្កាឈូក សង្ស័យថាគ្រឿងញៀនទម្ងន់ ១៨៣៨,៤ក្រាម (មួយពាន់ប្រាំបីរយសាមសិបប្រាំបីក្បៀសបួនក្រាម) និងសម្ភារៈចាប់យករួមមានទូរស័ព្ទដៃម៉ាក S-wellcom មួយគ្រឿង។

លុះដល់វេលាម៉ោង ១៤:២៥នាទី នាថ្ងៃខែឆ្នាំដដែល កម្លាំងចម្រុះបានបន្តធ្វើការឆែកឆេរបន្ទប់លេខ ១៣ ក្នុងផ្ទះសំណាក់ផ្ការមាស សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងបានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបែ ដែលជាអ្នកជួញដូរគ្រឿងញៀនជាមួយឈ្មោះ [redacted] ខាំ ជាជនជាតិភូមា និងឈ្មោះ ផល្លី ព្រមទាំងឈ្មោះ សម្រស់ តាមការចង្អុលបង្ហាញរបស់ឈ្មោះ [redacted] ថង និងបានចាប់យកសម្ភារៈរួមមាន រថយន្តមួយគ្រឿង ម៉ាក TOYOTA VIGO ពណ៌ស ស្លាកលេខឡាវ ៣៩៧៥ ទូរស័ព្ទដៃម៉ាក NOKIA ចំនួនមួយគ្រឿង, ទូរស័ព្ទដៃគ្មានម៉ាកចំនួនមួយគ្រឿង, លិខិតឆ្លងដែនចំនួនពីរច្បាប់, កូនសៀវភៅចំនួនពីរក្បាល, បណ្ណធនាគារចំនួនពីរច្បាប់ និងអត្តសញ្ញាណប័ណ្ណចំនួនមួយច្បាប់ ដើម្បីកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមច្បាប់។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០១ កប.១ "ឃ" ចុះថ្ងៃទី២៣-០១-២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថាៈ

I-ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោមៈ



Scanned with CamScanner

135/9

ក-ឈ្មោះ [redacted] គុមភន់ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិឡាវ

ខ-ឈ្មោះ [redacted] ខាំបែ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិឡាវ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ២៥ (ម្ភៃប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួន (២៣-១២-២០១២) និងពិន័យជាប្រាក់ក្នុងម្នាក់ៗកំណត់ចំនួន ៥០.០០០.០០០៛ (ហាសិបលាន)រៀល ដាក់ចូលថវិការរដ្ឋ។

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារ បូលីណាជាឡេស ផ្លូវលេខ ១៥៥ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

គ-ឈ្មោះ [redacted] ថង ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ

ឃ-ឈ្មោះ [redacted] ស៊ិត ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ២០ (ម្ភៃ)ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួន (២៣-១២-២០១២) និងពិន័យជាប្រាក់ក្នុងម្នាក់ៗកំណត់ចំនួន ៥០.០០០.០០០៛ (សែសិបលាន)រៀល ដាក់ចូលថវិការរដ្ឋ។

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារ បូលីណាជាឡេស ផ្លូវលេខ១៥៥ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

II-បណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីទណ្ឌិតឈ្មោះ [redacted] គុមភន់ និង ឈ្មោះ [redacted] ខាំបែ អនុវត្តទោសពន្ធនាគារ និងទោសពិន័យជាប្រាក់ចប់សព្វគ្រប់ជាស្ថាពរ តាមអំណាចសាលក្រមនេះរួច តាមមាត្រា ៦១ នៃក្រមព្រហ្មទណ្ឌ។

III-វត្ថុចាប់យកតាមកំណត់ហេតុទទួលវត្ថុតាងពីចៅក្រមស៊ើបសួរលេខ ៧៧០វត ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ រួមមាន៖

ក-ប្រភេទថ្នាំគ្រាប់ពណ៌ផ្កាឈូកសង្ស័យថា គ្រឿងញៀនទម្ងន់ ១៨៣៨,៤ក្រាម (មួយពាន់ ប្រាំបីរយសាមសិបប្រាំបីក្បៀសបួនក្រាម) គប្បីសម្រេចរឹបអូសបំផ្លាញចោល តាមមាត្រា ៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-រថយន្តមួយគ្រឿងម៉ាក TOYOTA VIGO ពណ៌ស ស្លាកលេខឡាវ ៣៩៧៥, រឹបអូស តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

គ-ទូរស័ព្ទដៃម៉ាក Wellcom-S101 មួយគ្រឿង, ទូរស័ព្ទដៃម៉ាក NOKIA ចំនួនមួយគ្រឿង, ទូរស័ព្ទដៃគ្មានម៉ាកចំនួនមួយគ្រឿង លិខិតឆ្លងដែនចំនួនពីរក្បាល, កូនសៀវភៅចំនួនពីរក្បាល, កាតមានអក្សរឡាវលេខ ៨៨៨៨៨ ៨៣០០០២៤ ចំនួនមួយសន្លឹក, កាតមានអក្សរឡាវលេខ



Scanned with CamScanner

A1-0040165 និងស៊ីមកាតចំនួនប្រាំ ប្រគល់ឲ្យម្ចាស់ដើមនៃទ្រព្យវិញ តាមមាត្រា ៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ចំពោះមុខជនជាប់ចោទទាំងបួន និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៨០ ចុះថ្ងៃទី០៣-០២-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ផង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០១ កប.១ (ឃ) ចុះថ្ងៃទី២៣-០១-២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៨១ ចុះថ្ងៃទី០៣-០២-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុត ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០១ កប.១ (ឃ) ចុះថ្ងៃទី២៣-០១-២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៨២ ចុះថ្ងៃទី០៣-០២-២០១៤ របស់ជនជាប់ចោទឈ្មោ [redacted] ខាំបៃ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០១ កប.១ (ឃ) ចុះថ្ងៃទី២៣-០១-២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៨៣ ចុះថ្ងៃទី០៣-០២-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] គុមភន់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០១ កប.១ (ឃ) ចុះថ្ងៃទី២៣-០១-២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រV "ប.ស" ចុះថ្ងៃទី១៨-១១-២០១៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨០, ៨១ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ផង, ឈ្មោះ [redacted] ស៊ុត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨២, ៨៣ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងរបស់ឈ្មោះ [redacted] គុមភន់ ទុកជាត្រឹមត្រូវតាមច្បាប់។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០១ កប១ "ឃ" ចុះថ្ងៃទី២៣-០១-២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាការដដែល លើកលែងទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] គុមភន់ ក្នុងចំណុចទី ១ក ត្រូវកែប្រែពីទោសអនុវត្តពន្ធនាគារ ២៥ (ម្ភៃប្រាំឆ្នាំ) មកដាក់ពន្ធនាគារកំណត់ ២២ (ម្ភៃពីរឆ្នាំ) និងចំណុចទី ១ខ លើឈ្មោះ [redacted] ខាំបៃ ត្រូវកែប្រែលើទោសអនុវត្តក្នុងពន្ធនាគារ ២៥ (ម្ភៃប្រាំឆ្នាំ) មកដាក់ពន្ធនាគារកំណត់ ២៤ (ម្ភៃបួនឆ្នាំ) វិញ។

ចំណុចផ្សេងពីនេះរក្សាទុកដដែល។

៤-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ថង, ឈ្មោះ[redacted]ស៊ិត និងឈ្មោះ[redacted]ខាំបៃ កំបាំងមុខជនជាប់ចោទឈ្មោះ អាំផន គុមកន់ ប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥។

បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

-បានឃើញ សេចក្តីសុំប្តឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី២៣-១២-២០១៥ របស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្តឹងសាទុក្ខនឹងសាលដីកា ព្រហ្មទណ្ឌលេខ ១២២ ក្រV "ប.ស" ចុះថ្ងៃទី១៨-១១-២០១៥ របស់សាលាឧទ្ធរណ៍។

-បានឃើញ សេចក្តីសុំប្តឹងសាទុក្ខលេខ ១៨៨ ចុះថ្ងៃទី១១-១២-២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted]ស៊ិត ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រV "ប.ស" ចុះថ្ងៃទី១៨-១១-២០១៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូល។

-បានឃើញ សេចក្តីសុំប្តឹងសាទុក្ខលេខ ២៧៣ ចុះថ្ងៃទី០៤-១២-២០១៥ របស់លោក [redacted] ទ្រី និងលោក [redacted] សុជាតិ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] គុមកន់ ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រV "ប.ស" ចុះថ្ងៃទី១៨-១១-២០១៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូល។

-បានឃើញ សេចក្តីសុំប្តឹងសាទុក្ខលេខ ២៨៦ ចុះថ្ងៃទី១១-១២-២០១៥ របស់ជនជាប់ចោទឈ្មោះ[redacted]ថង ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រV "ប.ស" ចុះថ្ងៃទី១៨-១១-២០១៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូល។

-បានឃើញ សេចក្តីសុំប្តឹងសាទុក្ខលេខ ២៨៧ ចុះថ្ងៃទី១១-១២-២០១៥ របស់ជនជាប់ចោទឈ្មោះ[redacted] ខាំបៃ ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រV "ប.ស" ចុះថ្ងៃទី១៨-១១-២០១៥ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូល។

–បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៣៧ ចុះថ្ងៃទី៣០–០១–២០១៨ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា៖

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៨៨ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted]ស៊ិត, បណ្តឹងសាទុក្ខលេខ ២៨៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ [redacted]ថង និងបណ្តឹងសាទុក្ខលេខ ៣០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

២-ទទួលបណ្តឹងសា/ទុក្ខលេខ ២៨៧ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ របស់ជនជាប់ចោទឈ្មោះ[redacted]ខាំបៃ និងបណ្តឹងសាទុក្ខលេខ ២៧៣ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ របស់លោក [redacted] ទ្រី និងលោក[redacted]សុជាតិ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted]គុមកន់។

៣-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រV "ប.ស" ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែសេចក្តីសម្រេចត្រង់ចំណុចទី៣ នៃសាលដីកា



Scanned with CamScanner

នេះ ពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបៃ ត្រូវបដិសេធចោល។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ២០ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះឡើងវិញ ត្រង់ចំណុចបដិសេធខាងលើ។

៥-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨។

-បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី២៣-៥-២០១៨ របស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍។

-បានឃើញ សេចក្ដីសន្និដ្ឋានបន្ថែម ចុះថ្ងៃទី១១-៦-២០១៨ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿង៖

-ជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបៃ (វត្តមាន)

-មេធាវីការពារសិទ្ធិ លោក [redacted] គីមហ៊ុច (វត្តមាន)

-អ្នកបកប្រែឈ្មោះ [redacted] ចាន់សុជា (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងជនជាប់ចោទឈ្មោះ [redacted] ខាំបៃ បានឆ្លើយបញ្ជាក់ដូចគ្នាថា: ខ្លួនទាំងពីរនាក់បានមកស្នាក់ នៅបន្ទប់សណ្ឋាគារជាមួយគ្នានៅពេលសមត្ថកិច្ចចាប់ខ្លួនបាន នៅនឹងខ្លួនៗមិនមានគ្រឿងញៀនទេ ការដែលខ្លួនមកពីប្រទេសឡាវ គឺមកជាមួយមិត្តភ័ក្រម្នាក់ ហើយក៏មកដើម្បីទិញថ្នាំព្យាបាលជើង ហើយក៏មកកម្ពុជានេះជាលើកទី១ ដែរ។ ចំពោះឈ្មោះ [redacted] ស៊ុត, [redacted] ថង ក៏ខ្លួនមិនដែលស្គាល់ដែរ ទើបតែមកស្គាល់នៅពេលសមត្ថកិច្ចចាប់ខ្លួននេះប៉ុណ្ណោះ។ ការដែលខ្លួនមកកម្ពុជានេះ គឺមានលិខិតឆ្លងដែនត្រឹមត្រូវ ហើយធ្វើដំណើរតាមច្រកកោះក្រឡ ខេត្តស្ទឹងត្រែង មិនមែនមកតាមខេត្តព្រះវិហារនោះទេ ការដែលនៅប៉ូលីសនោះ មិនដឹងអ្នកបកប្រែយ៉ាងម៉េច ត្រឡប់ចុះត្រឡប់ឡើងខ្លួនមិនយល់ចំពោះរឿងគ្រឿងញៀននោះខ្លួនមិនបានដឹងទេ នៅពេលដែលប៉ូលីសចាប់ខ្លួនរួចហើយ គេក៏យកគ្រឿងញៀននោះមកចាក់នៅមុខពួកខ្លួន ការដែលខ្លួនផ្ដិតមេដៃនៅប៉ូលីសនោះ ដោយគេប្រាប់ខ្លួនថា ខ្លួនអត់មានពាក់ព័ន្ធនឹងរឿងគ្រឿងញៀនអីទេ ឲ្យខ្លួនផ្ដិតមេដៃទៅ គេនឹងដោះលែងខ្លួនៗក៏ផ្ដិតមេដៃ។ ការដែលខ្លួនមកកម្ពុជានេះ ក្រៅពីទិញថ្នាំដើម្បីព្យាបាលជើង នៅមានទិញគ្រឿងអគ្គិសនីមួយចំនួនទៀត។ ការដែលខ្លួនមកភ្នំពេញ គឺមកជាមួយឈ្មោះ ផល្លី ប៉ុន្តែមុនដំបូងខ្លួនមិនស្គាល់ឈ្មោះទេ ដោយជិះឡានជាមួយគ្នា ក្រោយពីទិញគ្រឿងអគ្គិសនីរួចហើយក៏នាំគ្នាទៅហូបបាយ ហូបបាយរួចក៏នាំគ្នាទៅរកបន្ទប់ដេក ដោយ ផល្លី ដេកបន្ទប់មួយឯខ្លួនពីរនាក់ដេកបន្ទប់មួយ រួចហើយប៉ូលីសមកចាប់តែម្ដង។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា:

ពាក់ព័ន្ធនឹងរឿងនេះ ក្រោយពីបានស្តាប់ការសួរដេញដោលនៅក្នុងអង្គសវនាការ គឺចម្លើយរបស់គាត់នៅសមត្ថកិច្ចប៉ូលីសមានពាក់ព័ន្ធនឹងឈ្មោះ [redacted] ថង, [redacted] ស៊ុត រឿងគ្រឿងញៀន និងជាមួយឈ្មោះ ផល្លី ប៉ុន្តែពេលដល់តុលាការសាលាដំបូង គាត់បានឆ្លើយបដិសេធ ពេលមកដល់សាលាឧទ្ធរណ៍ ក៏គាត់ឆ្លើយបដិសេធដែរ ហេតុដូច្នេះតំណាងមហាអយ្យការសុំទុកសិទ្ធិជូនក្រុមប្រឹក្សាពិនិត្យពិចារណា ហើយសម្រេចតាមការចង្អុលបង្ហាញរបស់តុលាការកំពូល។

-មេធាវីធ្វើសេចក្តីសន្និដ្ឋានថា:

-លោក [redacted] គឹមហ៊្កិច ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានសន្និដ្ឋានថា: ក្រោយពីបានសិក្សាសំណុំរឿងនេះរួចមក កន្លងមកឃើញថា តុលាការកំពូលបានបង្វិលសំណុំរឿងនេះ ដើម្បីឲ្យតុលាការសាលាឧទ្ធរណ៍វិនិច្ឆ័យទៅលើរឿងក្តីនេះបន្តទៀត ដោយសារតែតុលាការកំពូលមានការសង្ស័យថា តើកូនក្តីខ្លួនត្រូវបានជួញដូរថ្នាំញៀនដែរឬទេ? ម្យ៉ាងទៀតតុលាការកំពូលចង្អុលបង្ហាញមកតុលាការសាលាឧទ្ធរណ៍ ពិនិត្យមើលថា តើឈ្មោះ សម្រស់ ជាអ្នកណា ត្រង់ចំណុចនេះក្រោយពីបានសិក្សាសំណុំរឿងកន្លងមក ខ្លួនសុំបង្ហាញនូវអង្គហេតុជូនតុលាការមេត្តាជ្រាបឲ្យបានច្បាស់។ កូនក្តីខ្លួនគាត់ជាជនជាតិឡាវ គាត់អត់ចេះភាសាខ្មែរទេ ពេលគាត់មកពីឡាវ គឺមកតាមខេត្តស្ទឹងត្រែង ហើយជួបឈ្មោះ ផល្លី ថា ជូនមកទិញគ្រឿងអគ្គិសនី និងទិញថ្នាំដើម្បីព្យាបាលជើងរបស់គាត់ដែលឈឺ នៅពេលមកដល់ព្រែកលៀប ក៏ចូលទៅស្នាក់នៅបន្ទប់ផ្សេងគ្នា ផល្លី ស្នាក់នៅបន្ទប់មួយផ្សេង ឯកូនក្តីខ្លួនពីរនាក់នេះស្នាក់នៅបន្ទប់លេខ ១៣ ប៉ុន្តែអ្វីដែលជាថ្នាំញៀនដែលសមត្ថកិច្ចចាប់បាននោះ គឺចាប់បាននៅបន្ទប់លេខ ៥០៣ សណ្ឋាគារ បូលីណាផាឡេស នៅផ្សារថ្មីឯណោះ ដោយចាប់បានពីឈ្មោះ [redacted] ថង និង [redacted] ស៊ុត ពេលនោះឈ្មោះ [redacted] ថង និងឈ្មោះ [redacted] ស៊ុត គាត់បាននិយាយរួចហើយថា គាត់បានស្គាល់ឈ្មោះ សម្រស់ ហើយឈ្មោះ សម្រស់ គឺជាអ្នកជូនគាត់មកធ្វើការជាជាងសំណង់ នៅភ្នំពេញ នៅពេលឈ្មោះ សម្រស់ ជូនគាត់មក គឺឈ្មោះ សម្រស់ ជាអ្នកទៅជួលបន្ទប់លេខ ៥០៣ នោះឲ្យគាត់ស្នាក់នៅ ហើយឈ្មោះ សម្រស់ ក៏បានទុកកាបូបមួយនៅក្នុងបន្ទប់របស់គាត់ នៅពេលដែលឈ្មោះ [redacted] ថង, [redacted] ស៊ុត នៅក្នុងបន្ទប់ ហើយឈ្មោះ សម្រស់ ចេញទៅបានប្រហែល ១៥នាទី សមត្ថកិច្ចក៏ចាប់ខ្លួនគាត់ ដោយយកទាំងកាបូបនោះទៅជាមួយផង នៅពេលទៅដល់មន្ទីរប្រឆាំងគ្រឿងញៀន សមត្ថកិច្ចក៏ស្រាយកាបូបនោះ ហើយកំណត់ថា ថ្នាំញៀននៅបន្ទប់លេខ ៥០៣ នោះ។ ហេតុដូច្នេះមានភាពផ្ទុយគ្នារវាងឈ្មោះ [redacted] ថង, [redacted] ស៊ុត គាត់មកតាមផ្លូវពីខេត្តព្រះវិហារ ឯកូនក្តីខ្លួនមកពីខេត្តស្ទឹងត្រែង ប៉ុន្តែមានមនុស្សស្រីពីរនាក់ តាមឈ្មោះ [redacted] ថង និង [redacted] ស៊ុត ឯកូនក្តីខ្លួន មានឈ្មោះ ផល្លី មកជាមួយកូនក្តីខ្លួន ដោយជូនមកទិញថ្នាំព្យាបាលរោគឲ្យឈ្មោះ [redacted] ខាំបៃ យើងពិនិត្យឃើញថា តើពីរនាក់នោះជាអ្នកណា? លោក [redacted] ដារ៉ាត់ ដែលជាមន្ត្រីប្រឆាំងគ្រឿងញៀន គាត់បានបញ្ជាក់ប្រាប់តុលាការថា គឺជាវិធានញុះញង់ ដើម្បីឲ្យលក់គ្រឿងញៀន តើអ្នកណា



Scanned with CamScanner

ម្នាក់ដែលចូលទៅក្នុងការញុះញង់ឲ្យលក់គ្រឿងញៀននោះ យើងឃើញមានតែពីរនាក់ទេ គឺឈ្មោះ ផល្លី និងឈ្មោះ សម្រស់ ដែលចូលទៅក្នុងវិធានញុះញង់នេះ ចំពោះឈ្មោះ សម្រស់ ទៅជាមួយឈ្មោះ [redacted]ង និង[redacted]ប៊ុត កាន់ថ្នាំញៀនទៅ ឯឈ្មោះ ផល្លី លោក[redacted]ដារ៉ាត់ បានបញ្ជាក់យ៉ាងច្បាស់ហើយថា មកជួបកូនក្តីខ្លួន ដើម្បីពិនិត្យមើលលុយ ដូច្នេះហើយសំដីដែលលោក [redacted]ដារ៉ាត់ បាននិយាយ គឺជាភស្តុតាងច្បាស់លាស់ ដែលគាត់បានបញ្ជាក់នៅសាលាដំបូងថា ឈ្មោះ ផល្លី មកដើម្បីមើលលុយកូនក្តីខ្លួន ក៏ប៉ុន្តែនៅពេលដែលចាប់ អត់ឃើញបានលុយកូនក្តីខ្លួនមួយរៀលទេ គឺបានតែលិខិតឆ្លងដែន និងរថយន្ត និងទូរស័ព្ទ ឯចំណែកលុយគឺមានប្រហែល ២.០០០$ (ពីរពាន់ដុល្លារអាមេរិក) ដើម្បីមកទិញសម្ភារៈរបស់គាត់តែប៉ុណ្ណោះ ហើយគាត់ទិញអស់ហើយ អត់មានលុយនៅនឹងខ្លួនគាត់ទៀតទេ ដូច្នេះសំដីរបស[redacted]ដារ៉ាត់ គឺជាភស្តុតាង ដើម្បីដោះបន្ទុកកូនក្តីខ្លួនហើយ នៅពេលដែលគាត់ឆ្លើយថាឈ្មោះ ផល្លី មករាប់លុយនៅចំពោះមុខកូនក្តីខ្លួន ម្យ៉ាងវិញទៀតយើងឃើញថា តុលាការកំពូលលោកបានបញ្ជាក់រួចហើយថា សូមឲ្យតុលាការថ្នាក់ក្រោមពិនិត្យមើលថា តើឈ្មោះ សម្រស់ ជាអ្នកណា? ឃើញថាឈ្មោះ សម្រស់ គឺគាត់ជាអ្នកកាន់គ្រឿងញៀនយកទៅដាក់បន្ទប់[redacted] ផង និង [redacted] ស៊ុត។ យើងពិនិត្យមើលមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន លុះត្រាតែកូនក្តីខ្លួនបានជួញដូរ រក្សាទុក និងកាន់គ្រឿងញៀន ទើបអាចដាក់ទណ្ឌកម្មកូនក្តីខ្លួនបាន ក៏ប៉ុន្តែនៅពេលដែលទៅចាប់នៅបន្ទប់លេខ ១៣ អត់បានអីសោះ បានតែទូរស័ព្ទ លិខិតឆ្លងដែន និងរថយន្តតែប៉ុណ្ណោះ។ កូនក្តីខ្លួនបានឆ្លើយបញ្ជាក់ជូនក្រុមប្រឹក្សាអំបាញ់មិញរួចហើយថា ការដែលប៉ូលីសចាប់គាត់យកទៅ អត់មានអ្នកបកប្រែឲ្យបានច្បាស់ទេ ហើយឲ្យផ្តិតមេដៃ ដោយប្រាប់គាត់ថាឲ្យផ្តិតមេដៃទៅអត់មានពាក់ព័ន្ធនឹងរឿងគ្រឿងញៀនអីទេ ឲ្យគាត់ត្រឡប់ទៅផ្ទះវិញ គាត់ក៏ផ្តិតមេដៃទៅ។ លុះមកដល់សាលាដំបូង មានអ្នកបកប្រែច្បាស់លាស់ កូនក្តីខ្លួនស្តាប់បាន គាត់ក៏ឆ្លើយបដិសេធរហូតមកដល់ពេលនេះ។ ដូច្នេះកូនក្តីខ្លួនមិនបានពាក់ព័ន្ធនឹងរឿងគ្រឿងញៀនទេ ទោះបីមន្ទីរប្រឆាំងគ្រឿងញៀនមានវិធានញុះញង់ ដើម្បីឲ្យលក់គ្រឿងញៀន ឬផ្តល់គ្រឿងញៀន ឬមួយក៏ទិញគ្រឿងញៀន ក៏មិនពាក់ព័ន្ធដល់កូនក្តីខ្លួនដែរ ដោយមូលហេតុថា នៅពេលដែលសមត្ថកិច្ចចាប់ខ្លួន គ្រឿងញៀនក៏អត់បាន លុយក៏អត់បាន ហេតុដូច្នេះហើយសុំឲ្យតុលាការ មេត្តាពិចារណាទៅតាមអ្វីដែលតុលាការកំពូល បានចង្អុលបង្ហាញ ក្នុងនាមខ្លួនជាមេធាវីសុំឲ្យតុលាការមេត្តាឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

-សំណូមពរចុងក្រោយរបស់ជនជាប់ចោទទាំងពីរនាក់ សុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្លួនផង និងសុំឲ្យខ្លួនរួចផុតពីបទចោទប្រកាន់។

## សាលាឧទ្ធរណ៍

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍
## យល់ឃើញថា

១-សាលាឧទ្ធរណ៍មានសមត្ថកិច្ចទទួលជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៨៧៥ ចុះថ្ងៃទី២០-៤-២០១៨ ជាលើកទី២ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៣៧ ចុះថ្ងៃទី៣០-០១-២០១៨ របស់តុលាការកំពូល។

២-ក្រោមប្រតិបត្តិការចុះបង្ក្រាបបទល្មើសជួញដូរគ្រឿងញៀនខុសច្បាប់ កាលពីថ្ងៃទី ២៣-១២-២០១២ នៅចំណុចសណ្ឋាគារបូលីណាជាឡេស បន្ទប់លេខ ៥០៣ ផ្លូវលេខ ១៥៤ ចំណុចផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ផង និងឈ្មោះ [redacted] ស៊ុត រួមទាំងវត្ថុតាងថ្នាំញៀនប្រភេទគ្រាប់ផ្កាឈូក ទម្ងន់ ១៨៣៨,៥ក្រាម ដែលលាក់ទុកក្នុងកាបូបទុកប្រគល់ឲ្យម៉ូយ ក្រោមការបញ្ជារបស់ឈ្មោះ ផល្លី និងឈ្មោះ សម្រស់។ នៅថ្ងៃដដែល កម្លាំងសមត្ថកិច្ចចម្រុះបន្តទៅឆែកឆេរបន្ទប់លេខ ១៣ ផ្ទះសំណាក់ផ្កាមោស សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបែ ឆែករកពុំមានថ្នាំញៀនឡើយ។

៣-តាមលទ្ធផលនៃការស៊ើបអង្កេតរបស់តុលាការគ្រប់ជាន់ថ្នាក់ ពុំបានរកឃើញភស្តុតាងជាគ្រឿងញៀន ដែលមានវត្តមានជាមួយនឹងជនជាប់ចោទឈ្មោះ [redacted] ខាំបែ និងជនជាប់ចោទឈ្មោះ [redacted] គុមភន់ ឡើយ អ្នកដែលមានថ្នាំញៀនពិតប្រាកដ គឺឈ្មោះ ផល្លី និងឈ្មោះ សម្រស់ ជាម្ចាស់កាបូប ជួលឲ្យឈ្មោះ [redacted] ផង និងឈ្មោះ [redacted] ស៊ុត យួរឲ្យ មកភ្នំពេញ។

៤-តាមលិខិតលេខ ៤៨៩ របក ចុះថ្ងៃទី២៦-១២-២០១២ របស់មន្ទីរប្រឆាំងគ្រឿងញៀន បញ្ជាក់ជូនអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ថា ឈ្មោះ សម្រស់ ឈ្មោះ ផល្លី និងឈ្មោះ [redacted] ខាំ ជាមេក្លោងរកស៊ីជួញដូរគ្រឿងញៀនឆ្លងដែនខុសច្បាប់ រីឯឈ្មោះ [redacted] ខាំបែ និងឈ្មោះ [redacted] គុមភន់ ជាគូរកនជាមួយ។ ម្យ៉ាងវិញទៀតតាមចម្លើយឈ្មោះ [redacted] ស៊ុត និងឈ្មោះ [redacted] ផង បានឆ្លើយនៅនគរបាល និងនៅគ្រប់ដំណាក់កាលស៊ើបសួររបស់តុលាការគ្រប់ជាន់ថ្នាក់បញ្ជាក់ថា ថ្នាំញៀនដែលសមត្ថកិច្ចចុះបង្ក្រាប និងរឹបអូសបានជាក់ស្តែងកាលពីថ្ងៃទី២៣-១២-២០១២ នៅក្នុងបន្ទប់លេខ ៥០៣ សណ្ឋាគារបូលីណាជាឡេស ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ នោះ គឺជារបស់ឈ្មោះ សម្រស់ ដែលដាក់ក្នុងកាបូបឲ្យពួកខ្លួនជួយកាន់ យកមកប្រគល់ឲ្យម៉ូយនៅភ្នំពេញ។ ដូចនេះដើម្បីកំណត់ឲ្យបាននូវភាពស្អាតស្អំ និងភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោះ [redacted] ខាំបែ សាលាឧទ្ធរណ៍ គប្បីគោរពការចង្អុលបង្ហាញរបស់តុលាការកំពូល។

៥-តាមខ្លឹមសារលិខិត ១០០១ ឆ.ត ចុះថ្ងៃទី២៩-៦-២០១៨ របស់ការិយាល័យអន្តរាគមន៍ នៃមន្ទីរប្រឆាំងគ្រឿងញៀន បានឆ្លើយតបជូនសាលាឧទ្ធរណ៍វិញថា ឈ្មោះ ផល្លី និង សម្រស់ ជាភ្នាក់ងារមូលដ្ឋានសង្កាត់ និងឈ្មោះ [redacted] ខាំ ជាមេក្លោងជួញដូរគ្រឿងញៀនខុសច្បាប់ប្រាកដមែន។

៦-ផ្អែកលើចំណុចទី២, ៣, ៤ និងទី៥ ខាងលើ និងប្រកាសលេខ ០៩ កយ.ប្រក/០៦ ចុះថ្ងៃទី០៨-០២-២០០៦ របស់ក្រសួងយុត្តិធម៌ ស្តីពីនីតិវិធីនៃការប្រគល់ ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់ដោយខុសច្បាប់។ ក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍អាចកំណត់បានថា ការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] គុមភន់ និងឈ្មោ [redacted] ខាំបៃ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឃើញថា ស្ថិតនៅក្នុងភាពវិមតិសង្ស័យ នៃមាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញ។

៧-ពុំមានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ខាំបៃ និងឈ្មោះ អាំផន គុមភន់ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារបូលីណាផាឡេស ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣-១២-២០១២ ឡើយ។

៨-សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ មានលក្ខណៈត្រឹមត្រូវហើយ គប្បីក្រុមប្រឹក្សាលើកមកពិចារណា និងសម្រេចតាមការចង្អុលបង្ហាញរបស់តុលាការកំពូល។

៩-សេចក្តីសន្និដ្ឋានរបស់មេធាវី និងសំណូមពររបស់ជនជាប់ចោទ សុំឲ្យក្រុមប្រឹក្សាពិចារណា និងសម្រេចឲ្យកូនក្តីរបស់ខ្លួនរួចផុតពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារបូលីណាផាឡេស ផ្លូវលេខ ១៥៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣-១២-២០១២។

១០-សាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រV "ប.ស" ចុះថ្ងៃទី១៨-១១-២០១៥ របស់សាលាឧទ្ធរណ៍ ត្រូវតុលាការកំពូលសម្រេចបដិសេធខ្លះ និងទុកខ្លះ ពេលនេះសាលាឧទ្ធរណ៍គប្បីលើកយកផ្នែកខ្លះនៃសេចក្តីសម្រេច ដែលតុលាការកំពូលបង្វិលមកសាលាឧទ្ធរណ៍វិញ មកពិចារណាជាថ្មីតាមការចង្អុលបង្ហាញរបស់តុលាការកំពូល។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីៈ**

១-ទទួលជំនុំជម្រះជាលើកទី២ តាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៣៧ ចុះថ្ងៃទី៣០-០១-២០១៨ របស់តុលាការកំពូល។

២-ឲ្យឈ្មោះ [redacted] ខាំបៃ ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិឡាវ និងឈ្មោះ [redacted] គុមភន់ ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិឡាវ រួចផុតពីបទចោទប្រកាន់ ពីបទ ជួញដូរដោយខុសច្បាប់

នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ ៥០៣ សណ្ឋាគារប្លូលីណាផាឡេស ផ្លូវលេខ ១៥៨ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣-១២-២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-បង្គាប់ឲ្យដោះលែងជនត្រូវចោទឈ្មោះ [redacted] ខាំបៃ និងឈ្មោះ [redacted] គុមភក់ (មានសាវតាជាតិដូចខាងលើ) ពីពន្ធនាគារជាបន្ទាន់ បើអ្នកទាំងពីរនេះមិនត្រូវបានជាប់ឃុំពីបទល្មើសអ្វីផ្សេងទៀតទេ។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៦-៦-២០១៨ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦-៧-២០១៨។

-បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted], [redacted], [redacted], [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ២០១៨

បានឃើញ

ប្រធានក្រុមប្រឹក្សា

ក្រឡាបញ្ជី

[redacted]

[redacted]



Scanned with CamScanner